**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ ០៦៩១ ព.ណ.កសប

ថ្ងៃ សុក្រ ៩ រោច ខែ ពិសាខ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែឧសភា ឆ្នាំ ២០២០

## ជម្រាបមក

## លោក/លោកស្រីប្រធាន ក្រុមហ៊ុន ខេមបូឌា ស៊ុយហ្ស៊ុយគី ម៉ូធ័រ

**កម្មវត្ថុ:** ការបន្តសុពលភាពកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើ ទោចក្រយានយន្តនិងគ្រឿងបន្លាស់ និងរថយន្ត និងគ្រឿងបន្លាស់ ម៉ាក **SUZUKI** ដែលមានម៉ូដែលក្នុងបញ្ជីភ្ជាប់មកជាមួយនេះ ក្នុងព្រះរាជាណាចក្រកម្ពុជា របស់ក្រុមហ៊ុន **ខេមបូឌា ស៊ុយហ្ស៊ុយគី ម៉ូធ័រ**។

**យោង:**
- មាត្រា ៣ និងមាត្រា ១១ នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- លិខិតរបស់ក្រុមហ៊ុន **ខេមបូឌា ស៊ុយហ្ស៊ុយគី ម៉ូធ័រ** ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០
- លិខិតកត់ត្រាទទួលស្គាល់សិទ្ធិផ្តាច់មុខលេខ ០៥០៩ ព.ណ កសប ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៨
- លិខិតប្រគល់សិទ្ធិផ្តាច់មុខរបស់ក្រុមហ៊ុន SUZUKI MOTOR CORPORATION ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មី លេខចុះបញ្ជី KH/៣៣៦៦/៩៣ ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៣។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោក/លោកស្រីប្រធានថា ក្រសួងពាណិជ្ជកម្មឯកភាពបន្តសុពលភាពកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើទោចក្រយានយន្តនិងគ្រឿងបន្លាស់ និងរថយន្តនិងគ្រឿងបន្លាស់ ពាក់ម៉ាក និងម៉ូដែលខាងលើក្នុងព្រះរាជាណាចក្រកម្ពុជារបស់ក្រុមហ៊ុន **ខេមបូឌា ស៊ុយហ្ស៊ុយគី ម៉ូធ័រ** ដែលទទួលបានពីក្រុមហ៊ុន SUZUKI MOTOR CORPORATION ដូចមានចែងក្នុងលិខិតប្រគល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខដែលក្រសួងបានតម្កល់ទុករួចហើយ។

លិខិតបន្តសុពលភាពកត់ត្រា និងតម្កល់សិទ្ធិផ្តាច់មុខនេះ មានសុពលភាពរយៈពេល ០២(ពីរ)ឆ្នាំ ដោយគិតចាប់ពីថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ២០២០ ហើយអាចនឹងត្រូវបាត់បង់សុពលភាពជាស្វ័យប្រវត្តិមុនកាលបរិច្ឆេទផុតកំណត់ខាងលើ ប្រសិនបើមានការជូនដំណឹងអំពីការបញ្ចប់សិទ្ធិពីក្រុមហ៊ុន SUZUKI MOTOR CORPORATION ដែលជាម្ចាស់ម៉ាក។

នីតិបុគ្គលដែលទទួលបានសិទ្ធិនាំចូល និងចែកចាយផ្តាច់មុខ ត្រូវបោះពុម្ពផ្សាយលិខិតកត់ត្រានេះក្នុងទំព័រខាងមុខសារព័ត៌មានល្បីៗភ្លាមយ៉ាងតិចចំនួន ៣(បី) លេខជាប់ៗគ្នា និងត្រូវអនុវត្តឲ្យបានត្រឹមត្រូវនូវលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អាស្រ័យហេតុនេះ សូមលោក/លោកស្រីប្រធានក្រុមហ៊ុន ជ្រាបជាព័ត៌មាន ។

**ជ. រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**រដ្ឋលេខាធិការ**

**អ៊ុក-ប្រជា**

*ចម្លងជូន:*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោ** នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី **ស ខេង***
- *ខុទ្ទកាល័យ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ*
- *ខុទ្ទកាល័យ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
- *អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ*
- *អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា*
- *អគ្គនាយកដ្ឋានពន្ធដារ*
- *ឯកសារ - កាលប្បវត្តិ*

# បញ្ជី

## ម៉ូដែលភ្ជាប់នឹងលិខិតកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខ

| ល.រ | ឈ្មោះ ម៉ូដែល |
|---|---|
| **រថយន្ត** | |
| 1 | Suzuki Grand Vitara |
| 2 | Suzuki Vitara |
| 3 | Suzuki Jimny |
| 4 | Suzuki Swift |
| 5 | Suzuki Celerio |
| 6 | Suzuki Ertiga |
| 7 | Suzuki XL7 |
| 8 | Suzuki Carry |
| **ទោចក្រយានយន្ត** | |
| 1 | Suzuki Smash |
| 2 | Suzuki NEX |
| 3 | Suzuki NEX II |
| 4 | Suzuki Let’s |
| 5 | Suzuki Viva |
| 6 | Suzuki Address |
| 7 | Suzuki Raider |
| 8 | Suzuki Burgman |
| 9 | Suzuki GD110 |
| 10 | Suzuki GSX |
| 11 | Suzuki Gixxer |